# ម៉ូឌុលទី ៩

# ការអភិវឌ្ឍផ្លូវចិត្ត-សង្គមរបស់កុមារ

# សៀវភៅបណ្តុះបណ្តាល ស.ព.ជ.ក.ស

## ម៉ូឌុល ៩ ការអភិវឌ្ឍផ្លូវចិត្ត-សង្គមរបស់កុមារ

| មេរៀន | វត្ថុបំណងនៃការសិក្សា | ម៉ោង |
|---|---|---|
| ១. ការណែនាំ និងការធ្វើតេស្តមុនពេលសិក្សា | • រៀបរាប់អំពីវត្ថុបំណងនៃការសិក្សាសម្រាប់ម៉ូឌុលនេះ។<br>• កំណត់ពីកម្រិតចំណេះដឹងរបស់សិក្ខាកាម តាមរយៈការអនុវត្តការធ្វើតេស្តមុនពេលសិក្សា។ | ៣០នាទី |
| ២. ការអភិវឌ្ឍផ្លូវ-សង្គមរបស់កុមារ | • រៀបរាប់ពីសារៈសំខាន់នៃការអភិវឌ្ឍផ្លូវចិត្ត-សង្គមសម្រាប់កុមារ | ១ម៉ោង ១៥នាទី |
| ៣. ដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារ | • រៀបរាប់អំពីដំណាក់កាលនៃការលូតលាស់របស់កុមារ និងវិធីនានាដើម្បី ជួយដល់ការលូតលាស់របស់កុមារ ទៅតាមអាយុ<br>• ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវសន្លឹកផ្ទាត់គន្លឹះ១២យ៉ាងសម្រាប់សុខភាពគ្រួសារ និងប័ណ្ណជំនួយការងារ | ៣ម៉ោង ៣០នាទី |
| ៤. ការបង្ហាញសេចក្តីស្រឡាញ់ | • កំណត់ និងបង្ហាញពីវិធីផ្សេងៗដើម្បីបង្ហាញសេចក្តីស្រឡាញ់ | ១ម៉ោង |
| ៥. ការផលិតឧបករណ៍បន្លឺសូរសម្លេង | • រៀនអំពីរបៀបធ្វើឧបករណ៍បន្លឺសូរសម្លេងសម្រាប់ទារកអាយុ 0 ដល់ ១២ខែ លេង។ | ១៥នាទី |
| ៦. ការផលិតវត្ថុរំយោល | • រៀនអំពីរបៀបធ្វើវត្ថុរំយោលសម្រាប់ទារកអាយុ 0 ដល់ ៦ខែ លេង។ | ៣០នាទី |
| ៧. ការផលិតរថយន្ត/ឡាន | • រៀនអំពីរបៀបធ្វើ រថយន្ត/ឡានកុមារលេងសម្រាប់កូនកុមារអាយុពី ៤-៥ឆ្នាំ | ១ម៉ោង ៣០នាទី |
| ៨. សង្ខេបម៉ូឌុល និងការធ្វើតេស្តក្រោយពេលសិក្សា | • រៀបរាប់សារគន្លឹះ និងចំណុចសង្ខេបនៃម៉ូឌុលនេះ<br>• វាយតម្លៃចំណេះដឹងរបស់សិក្ខាកាមក្រោយវគ្គសិក្សា តាមរយៈបញ្ជីសំណួរតេស្តក្រោយពេលសិក្សា | ៣០នាទី |
| **សរុប** | | **៩ម៉ោង** |

❋ ថ្ងៃបណ្តុះបណ្តាលនីមួយៗមានរយៈពេលសរុប ៧ម៉ោង ដែររួមមាន:

- រយៈពេលបណ្តុះបណ្តាល ៦ម៉ោង (ពេលព្រឹក ៣ម៉ោង និងពេលថ្ងៃរសៀល ៣ម៉ោង)
- ១ ម៉ោង សម្រាប់អាហារសម្រន់ និងសកម្មភាពផ្សេងទៀត

ប័ណ្ណជំនួយការងារគន្លឹះ១២យ៉ាងសម្រាប់សុខភាពគ្រួសារ

សម្រាប់ម៉ូឌុលទី៩  ការអភិវឌ្ឍផ្លូវចិត្ត-សង្គមរបស់កុមារ

(អាចទទួលបានពី  ម.ជ.ល.ស)



**កំណត់សំគាល់សម្រាប់អ្នកសម្របសម្រួល:**

ម៉ូឌុលនេះរួមមានទាំងជម្រើសសកម្មភាពសម្រាប់ការធ្វើប្រដាប់សម្រាប់ក្មេងលេងផងដែរ ។អ្នកសម្របសម្រួលអាចជ្រើសរើសដើម្បីបង្កើតឧបករណ៍ខ្លះៗទាំងអស់ឬអត់សោះសម្រាប់កុមារលេងដូចដែលបានលើកឡើង។ បើសិនអ្នកសម្របសម្រួលជ្រើសរើសសកម្មភាពខ្លះៗ ដើម្បីធ្វើពួកគេអនុវត្តត្រូវយល់ថា សកម្មភាពមួយចំនួនត្រូវការសម្ភារៈ ជាច្រើនដែលគួរត្រូវបានប្រមូលទុកមុនពេលការបណ្តុះបណ្តាលចាប់ផ្តើម។

អ្នកសម្របសម្រួលអាចសុំឱ្យអ្នកស្ម័គ្រចិត្តនាំយកសម្ភារៈមកជាមួយ ប៉ុន្តែត្រូវប្រាប់ពួកគេ១ខែមុន ដូច្នេះពួកគេមានពេលគ្រប់គ្រាន់ ដើម្បីប្រមូលសម្ភារៈទាំងនោះ។ តាមដែលអាចធ្វើបានរាល់សម្ភារៈទាំងអស់ដែលត្រូវបានប្រើដើម្បីបង្កើតប្រដាប់លេងនេះ អាចត្រូវរកនៅក្នុងមូលដ្ឋានហើយមិនមានតម្លៃថ្លៃ ឬបានដោយមិនអស់លុយ។ ពីព្រោះអ្នកស្ម័គ្រចិត្តសុខភាពភូមិនឹងអាចមិនមានសម្ភារៈគ្រប់គ្រាន់ សម្រាប់ការបង្រៀនទៅម្តាយៗរបស់ពួកគេទេ គំនិតមួយសម្រាប់អ្នកស្ម័គ្រចិត្ត រៀនអំពីរបៀបបង្កើតប្រដាប់កុមារលេងមួយឬច្រើន និងបង្ហាញវត្ថុទាំងនេះទៅម្តាយៗក្នុងសកម្មភាពប្រចាំខែរបស់ពួកគេ។ ប្រសិនបើមានម្តាយម្នាក់ចាប់អារម្មណ៍នឹងប្រដាប់កុមារលេងពិតៗនេះ អ្នកស្ម័គ្រចិត្តសុខភាពអាចសុំឱ្យម្តាយប្រមូលសម្ភារៈចាំបាច់ ហើយអ្នកស្ម័គ្រចិត្តនឹងបង្រៀនជាលក្ខណៈបុគ្គលតែម្តង។

## ដំបូន្មានទូទៅ

1. ការគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ ដូចដែលបានដាក់ចេញនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ សិទ្ធិកុមារទាំងនោះមិនមែនជាការគាបសង្កត់ដល់ក្រុមគ្រួសារឡើយ តែវាជាបន្ទុករបស់សង្គមទាំងមូល។
2. ការអភិវឌ្ឍរបស់កុមារនៅអាយុបីឆ្នាំដំបូង មានសារៈសំខាន់ខ្លាំងណាស់ ក្នុងការបង្កើតនូវមូលដ្ឋានគ្រឹះសម្រាប់ការរៀនសូត្រនៅដំណាក់កាលបន្ទាប់នៃជីវិត។ ដូចនេះមាតាបិតា អ្នកថែទាំកុមារ និងសហគមន៍ចាំបាច់ត្រូវធានាថា កុមារគ្រប់ៗរូបទទួលបាននូវតម្រូវការចាំបាច់ និងការអប់រំបានត្រឹមត្រូវគ្រប់ផ្នែក និងពេលលេញ។
3. មាតាបិតាចាំបាច់ត្រូវដឹងអំពីដំណាក់កាលនៃការលូតលាស់របស់កុមារ និងត្រូវស្វែងរកដំបូន្មានពីអ្នកធ្វើការទាក់ទងនឹងសុខភាពក្នុងសហគមន៍ដូចជាគ្រូមតេយ្យ/បឋម គិលានុប្បដ្ឋាក/យិកា វេជ្ជបណ្ឌិតឱ្យបានឆាប់រហ័ស នៅពេលកុមារលូតលាស់ខុសពីធម្មតាអាចការពារបានពីពិការភាពនៅអនាគតកាល។
4. គ្រូមត្តេយ្យ/បឋមសិក្សា អ្នកធ្វើការសុខភាពសហគមន៍ ត្រូវជួយផ្តល់ដំបូន្មានដល់មាតាបិតាអំពីការលូតលាស់របស់កុមារ និងការស្វែងរកសេវាសមស្រប។
5. មាតាបិតាជាគ្រូទីមួយ និងជាអ្នកទទួលខុសត្រូវដំបូងបង្អស់ដល់កូន។ មាតាបិតាអាចបំពេញតួនាទីរបស់ខ្លួនបានល្អប៉ុណ្ណោះនោះនឹងមានផលល្អដល់កូនរបស់ខ្លួនផ្ទាល់ ថែមទាំងដល់សហគមន៍ទាំងមូលផងដែរ។ មាតាបិតាមានពេលខ្លះក៏ត្រូវការ ការជួយពីអ្នកខាងក្រៅផងដែរ។
6. មាតាបិតាត្រូវដឹងផងដែរថា តើត្រូវផ្តល់នូវបរិស្ថានសមរម្យបែបណាដល់កូន ដើម្បីឱ្យកូនលូតលាស់ប្រកបដោយសុវត្ថិភាព និងសុខដមរម្យនាបានគ្រប់ផ្នែក។ ទាំងនេះត្រូវប្រាកដថា បរិយាកាសជុំវិញក្មេងមានសុវត្ថិភាព ហើយក្មេងទាំងនោះ ត្រូវបានការពារពីការមុតដោយរបស់ស្រួច រលាក ពុល ធ្លាក់/ដួល លង់ទឹក សត្វខាំ ឆក់ខ្សែភ្លើង និងបច្ច័យអាក្រក់ផ្សេងៗ។

**តម្រូវការជាមូលដ្ឋានរបស់កុមារតូចនៅវ័យបីឆ្នាំដំបូង រួមមាន:**

- ការការពារពីគ្រោះថ្នាក់ទាំងឡាយ
- ការផ្តល់អាហារូបត្ថម្ភគ្រប់គ្រាន់
- ការទទួលថ្នាំបង្ការបានគ្រប់ ( ចំនួនគ្រប់ត្រឹមត្រូវ ៥ដង )
- ការផ្តល់ភាពជិតស្និទ្ធនឹងមនុស្សចាស់
- មនុស្សចាស់ត្រូវយល់ពីតម្រូវការផ្លូវកាយ និងផ្លូវចិត្តរបស់កុមារ នឹងឆ្លើយតបទៅគេវិញ
- ការផ្តល់វត្ថុនានាដែលគេអាចមើលឃើញ ប៉ះពាល់ ស្តាប់ឮ ហិតក្លិន និងភ្លក់រស់ជាតិ
- ការផ្តល់ឱកាសឱ្យកុមារក្នុងការយល់ពីមជ្ឈដ្ឋានជុំវិញខ្លួនគេ
- ការជួយភ្ញោចផ្នែកភាសា
- ការជួយឱ្យឆាប់រៀនធ្វើចលនា ភាសា និងបំណិនក្នុងការគិតគូរ
- ការរៀនគ្រប់គ្រងឥរិយាបថខ្លួនការផ្តល់ឱកាសបានលេងសប្បាយ ។

**មាតាបិតាគឺជាមនុស្សសំខាន់បំផុតដល់ការលូតលាស់និងអភិវឌ្ឍរបស់កុមារ។ កុមារលូតលាស់ជាបន្តបន្ទាប់ និងពេញ លេញ នៅពេលដែលគេ:**

- ទទួលនូវសេចក្តីស្រឡាញ់ និងថែទាំដោយយកចិត្តទុកដាក់
- មានអ្នកស្តាប់នូវអ្វីៗដែលកុមារនិយាយ និងឆ្លើយតបមកគេវិញ
- មានឱកាសធ្វើចលនា និងហាត់ប្រាណ
- មានឱកាសលេង និងរុករកនូវអ្វីដែលថ្មី
- អាចមានទំនាក់ទំនងជាមួយអ្នកដទៃ
- ទទួលការសសើរ និងលើកទឹកចិត្ត

# គម្រោងមេរៀន

## ម៉ូឌុល ៩ ការអភិវឌ្ឍផ្លូវចិត្ត-សង្គមរបស់កុមារ

## មេរៀនទី ១: ការណែនាំ និងតេស្តមុនពេលសិក្សា រយៈពេល ៣០នាទី

**វត្ថុបំណងនៃការសិក្សា:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាចៈ

១. រៀបរាប់ពីវត្ថុបំណងនៃការសិក្សាសម្រាប់ម៉ូឌុលនេះ

២. កំណត់កម្រិតចំណេះដឹងរបស់សិក្ខាកាម តាមរយៈការធ្វើតេស្តមុនពេលសិក្សា

**សម្ភារៈជំនួយបង្រៀន:**

- ក្រដាសផ្ទាំងធំដែលមានសរសេរអំពីវត្ថុបំណងនៃការសិក្សាសម្រាប់ម៉ូឌុលនេះ
- សំណួរសម្រាប់ធ្វើតេស្តមុនពេលសិក្សា

**វិធីសាស្ត្របង្រៀន:**

- ការពន្យល់
- ការធ្វើតេស្តមុនពេលសិក្សា

**ជំហានសកម្មភាព:**

**បង្ហាញវត្ថុបំណងរួម**

**សេចក្តីផ្តើម:** អ្នកសម្របសម្រួលធ្វើការស្វាគមន៍ដល់សិក្ខាកាមទាំងអស់។ យើងសង្ឃឹមថា អ្នកទទួលបានបទពិសោធន៍ជាច្រើនកាលពីខែកន្លងមក ដូចជាអ្នកបានសាកល្បងនូវសកម្មភាពជាអ្នកស្ម័គ្រចិត្តសុខភាពភូមិ។ យើងនឹងអាចពិភាក្សាគ្នាអំពីបទពិសោធន៍ខ្លះៗរបស់អ្នកនៅពេលចុងថ្ងៃនេះ។ យើងពេញចិត្តនឹងស្តាប់យោបល់ និងគំនិតផ្សេងៗរបស់អ្នក។ នៅគ្រប់វគ្គបណ្តុះបណ្តាលមុនៗ យើងបានពិភាក្សាអំពីមធ្យោបាយ ដើម្បីថែទាំរាងកាយកុមារឱ្យមានសុខភាពល្អ។ ដូច្នេះសុខភាពរបស់កុមារផ្អែកទៅលើសុខភាពផ្លូវចិត្តរបស់ពួកគេក៏ដូចជាសុខភាពរាងកាយផងដែរ។ នេះមានន័យថា ដើម្បីឱ្យកុមារមានការលូតលាស់ល្អ និងមានប្រាជ្ញាឈ្លាសវៃ ពួកគេត្រូវតែជាមនុស្សរីករាយ (ដូចជាមនុស្សពេញវ័យ) សកម្មរួសរាយរាក់ទាក់មានគ្រួសារ គួរឱ្យស្រឡាញ់មានអ្វីៗសម្រាប់រៀន និងលេងដោយសុវត្ថិភាព។

**វត្ថុបំណងទី១: រៀបរាប់ពីវត្ថុបំណងនៃការសិក្សាសម្រាប់ម៉ូឌុលនេះ**

អ្នកសម្របសម្រួល ស្នើឱ្យសិក្ខាកាមម្នាក់ ឬពីរនាក់អានវត្ថុបំណងនៃការសិក្សាសម្រាប់ម៉ូឌុលដែលបានសរសេរដាក់លើក្រដាសផ្ទាំងធំជាស្រេច។ បន្ទាប់មកអ្នកសម្របសម្រួលសួរសិក្ខាកាម តើពួកគេមានសំណួរអ្វីឬទេ។

**វត្ថុបំណងទី២: កំណត់ពីកម្រិតចំណេះដឹងរបស់សិក្ខាកាមតាមរយៈការធ្វើតេស្តមុនពេលបណ្តុះបណ្តាល**

អ្នកសម្របសម្រួលប្រាប់ទៅសិក្ខាកាមថា មុនពេលយើងចាប់ផ្តើម យើងចង់ឱ្យអ្នកទាំងអស់គ្នាធ្វើតេស្តខ្លីមួយ។ ប្រហែលជាអ្នកនៅចាំបានថា កាលពីលើកមុនសំណួរតេស្តមុនពេលបណ្តុះបណ្តាលនេះ នឹងជួយអ្នកសម្របសម្រួល ឱ្យរកឃើញនូវវិធីសាស្ត្រល្អបំផុតដែលជួយដល់ការរៀនសូត្រនៅក្នុងវគ្គនេះ។ សូមកុំបារម្ភ ប្រសិនបើអ្នកមិនដឹងរាល់ចម្លើយទាំងអស់នោះទេ។ មុនពេលយើងចាប់ផ្តើម តើអ្នកមានសំណួរអ្វីទេ?

១. ចែកសំណួរតេស្តមុនពេលសិក្សាដល់សិក្ខាកាមម្នាក់មួយច្បាប់ និងសុំឱ្យពួកគេធ្វើរៀងៗខ្លួន។
២. រក្សាទុកពិន្ទុនេះ ដើម្បីប្រៀបធៀបជាមួយនឹងពិន្ទុតេស្តក្រោយពេលសិក្សា។

### សំណួរសម្រាប់ធ្វើតេស្តមុន និងក្រោយពេលសិក្សា

សំណួរ "ត្រូវ ឬ ខុស" (សំណួរត្រូវ ត្រូវបានបង្ហាញក្នុងប្រអប់ខៀវ)

| | | |
|---|---|---|
| ១. កុមារត្រូវការការជំរុញលើកទឹកចិត្ត (ការលេង ការជជែក ការរៀន) ដើម្បីឱ្យសប្បាយរីករាយ និងមានសុខភាពល្អ | ត្រូវ | ខុស |
| ២. កុមារដែលមានសុខភាពល្អ ហើយទទួលបាននូវក្តីស្រឡាញ់ នៅពេលកុមារនោះធំពេញវ័យ គេក៏អាចផ្តល់នូវក្តីស្រឡាញ់នោះដល់អ្នកដទៃទៀតដែរ | ត្រូវ | ខុស |
| ៣. សម្ភារៈសម្រាប់កុមារលេងមានសារៈសំខាន់ណាស់ ព្រោះសម្ភារៈទាំងនោះអាចជួយជំរុញដល់ស្មារតីរបស់កុមារ និងជួយឱ្យគេមានការលូតលាស់ផ្នែកបញ្ញា (ការគិត) | ត្រូវ | ខុស |
| ៤. ការញញឹម គឺជាមធ្យោបាយក្នុងការប្រាស្រ័យទាក់ទងដ៏សំខាន់មួយសម្រាប់ទារក និងកុមារ | ត្រូវ | ខុស |
| ៥. ទារក/កុមារត្រូវការសេចក្តីស្រឡាញ់ និងការថ្នាក់ថ្នមច្រើនដូចគ្នា | ត្រូវ | ខុស |
| ៦. ទារក/កុមារអាយុ ៧ខែ អាចធ្វើត្រាប់តាមសំលេង និងទឹកមុខរបស់មនុស្សធំ | ត្រូវ | ខុស |
| ៧. ទារក/កុមារអាយុ ១២ខែ អាចចាប់យកវត្ថុផ្សេងៗដោយម្រាមដៃ | ត្រូវ | ខុស |
| ៨. សុខភាពផ្លូវចិត្តរបស់ទារក/កុមារ មិនមានសារៈសំខាន់ដូចសុខភាពរាងកាយរបស់គេទេ | ត្រូវ | ខុស |
| ៩. ការស្រែកគំហក ការទះបន្តិចបន្តួច ពុំមែនជាអំពើហិង្សាទេ | ត្រូវ | ខុស |
| ១០. ការលង់ទឹក ជាពិសេសនៅស្រះទឹក អណ្តូងទឹក គឺជាមូលហេតុចម្បងដែលបណ្តាលឱ្យកុមារមានអាយុ ១-៤ ឆ្នាំស្លាប់នៅកម្ពុជា | ត្រូវ | ខុស |
| ១១. ប្រសិនបើទារក/កុមារមានការលូតលាស់ខុសពីទារក/កុមារដទៃ ឪពុកម្តាយគួរតែចាំមើលសិន ព្រោះវានឹងបាត់ទៅវិញដោយខ្លួនឯង។ | ត្រូវ | ខុស |

## មេរៀនទី ២: ការអភិវឌ្ឍផ្លូវចិត្ត-សង្គមរបស់កុមារ រយៈពេល: ១ម៉ោង ១៥នាទី

**វត្ថុបំណងនៃការសិក្សា:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាចៈ

១. រៀបរាប់ពីសារៈសំខាន់នៃការអភិវឌ្ឍផ្លូវចិត្ត-សង្គមរបស់កុមារ

**សម្ភារៈជំនួយបង្រៀន:**

- បាល់ក្រដាសដែលមានសរសេរសារសុខភាព
- សន្លឹកផ្ទាត់ គន្លឹះ១២យ៉ាងសម្រាប់សុខភាពគ្រួសារ

**វិធីសាស្រ្តបង្រៀន:**

- បំផុសគំនិត
- ល្បែងបាល់

**ជំហានសកម្មភាព:**

**បង្ហាញពីវត្ថុបំណងរួម:** សារៈសំខាន់នៃការអភិវឌ្ឍផ្លូវចិត្ត-សង្គមសម្រាប់កុមារ

**សេចក្តីផ្តើម**(ធ្វើការសន្ទនាបើអាចធ្វើបាន): ដូចមនុស្សពេញវ័យដែរ ទារក និងកុមារត្រូវការចំណង ផ្លូវចិត្តច្រើនដើម្បីឱ្យសប្បាយរីករាយ។ កុមារដែលទទួលបានចំណងផ្លូវចិត្តច្រើន ដូចជាការថ្នាក់ថ្នម ការជជែក និងការលេង។ល។ នឹងក្លាយទៅជាកុមារឆ្លាត ជឿជាក់លើខ្លួនឯង និងចាប់អារម្មណ៍នូវអ្វីៗជុំវិញខ្លួនរបស់វា។

**វត្ថុបំណងទី១: រៀបរាប់ពីសារៈសំខាន់នៃការអភិវឌ្ឍផ្លូវចិត្ត-សង្គមសម្រាប់កុមារ**

➢ **បំផុសគំនិត**

១. សុំឱ្យសិក្ខាកាម គិតអំពីអ្វីដែលធ្វើឱ្យកូនៗរបស់ពួកគេសប្បាយចិត្ត។ "តើធ្វើដូចម្តេចដើម្បីឱ្យកូនរបស់អ្នកបានសប្បាយចិត្ត?"សរសេរចម្លើយរបស់សិក្ខាកាមដាក់លើក្រដាសផ្ទាំងធំ។ បន្ទាប់មកពន្យល់ដល់សិក្ខាកាមអំពីចម្លើយដូចខាងក្រោម:

- ផ្តល់សេចក្តីស្រឡាញ់របស់គ្រួសារ
- រៀបចំឱ្យមានឧបករណ៍មានសុវត្ថិភាពឱ្យកូនលេងទៅតាមអាយុ និងលេងល្បែងជាមួយកូនរបស់អ្នក
- មានអ្នកជជែកជាមួយគ្នា
- ផ្តល់ឱកាសដល់កូន ឱ្យពួកគេបានលេងជាមួយមិត្តភក្តិ
- ផ្តល់ឱកាសដល់ពួកគេ ឱ្យទៅសាលារៀន និងរៀនសូត្រ

២. សួរទៅសិក្ខាកាមទាំងអស់ថា ហេតុអ្វីពួកគេគិតថា ចំណុចទាំងនេះធ្វើឱ្យកុមារសប្បាយចិត្ត? តើចំណុចទាំងអស់នេះ ធ្វើឱ្យកុមារគិត និងចាប់អារម្មណ៍ឬទេ?

៣. បន្ទាប់មកប្រាប់ទៅសិក្ខាកាមថា ពួកអ្នកនឹងត្រូវលេងល្បែងហុចបាល់បន្តគ្នា (បាល់ធ្វើពីក្រដាសដែលមានសរសេរសារលើក្រដាសតាមស្រទាប់នីមួយៗ)។ សិក្ខាកាមចាប់ផ្តើមហុចបាល់បន្តគ្នា នៅពេលអ្នកសម្របសម្រួលស្រែកថា "ឈប់" បើអ្នកណាមួយដែលកំពុងកាន់បាល់ក្រដាសនោះ ត្រូវបកមួយសន្លឹកក្រដាសស្រទាប់ផ្នែកខាងក្រៅបង្អស់នៃបាល់ និងអានសារនោះខ្លាំងៗឱ្យក្រុមស្តាប់ ។

៤. បន្ទាប់ពីសិក្ខាកាមអានព័ត៌មានរបស់គេ ហើយពួកគេគួរបិទនៅលើក្រដាសធំផ្ទាំងដែលមានសរសេរចំណងជើងថា "ការអភិវឌ្ឍផ្លូវចិត្ត-សង្គមរបស់កុមារ"។ បន្ទាប់មកបន្តល្បែងរហូតដល់អស់សារពីបាល់។

- បន្ទាប់ពីសារទាំងអស់ត្រូវបានបិទ សុំអ្នកស្ម័គ្រចិត្តម្នាក់អានខ្លាំងៗ ដើម្បីរំលឹកឡើងវិញ និងពិភាក្សាបន្ថែម។

**សារសម្រាប់ធ្វើល្បែងបាល់រួមមាន:**

- ម្តាយត្រូវតែបំបៅដោះកូនក្នុងអំឡុងពេល១ម៉ោងដំបូងបន្ទាប់ពីសម្រាល ព្រោះនេះជាចំណងផ្លូវចិត្តរវាងម្តាយ និងកូន។
- ត្រូវនិយាយលេងជាមួយទារកឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន ទោះបីជាទារកនោះនៅតូចក៏ដោយ ក៏ពួកគេអាចស្តាប់ ហើយអាចរៀននិយាយបានដែរ។ កុមារត្រូវការប្រដាប់ប្រដាសម្រាប់លេងដែលអាចជួយដល់ការអភិវឌ្ឍផ្នែកខួរក្បាល និងផ្នែករាងកាយ (ដៃ ជើង និងភ្នែក)។
- ទារកចូលចិត្តឱ្យគេថ្នាក់ថ្នមបីបម ដូច្នេះវាពុំមានអារម្មណ៍ឯកកោទេ។
- ការទៅសាលារៀនមានសារៈសំខាន់ចំពោះកុមារ ព្រោះអាចជួយគេក្នុងការរៀនសូត្រ និងបណ្តុះនូវភាពវ័យឆ្លាត។ ការញញឹមមានសារៈសំខាន់ណាស់ ព្រោះអាចបង្ហាញពីទឹកចិត្តសប្បាយរីករាយរបស់មនុស្ស។ ត្រូវញញឹមទៅរកទារក ឬកុមារឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។
- កុមារនឹងរីករាយនៅពេលមនុស្សដែលនៅជុំវិញខ្លួន ឬកុមារដទៃទៀតបានលេងជាមួយគេ។
- កុមារដែលមានអារម្មណ៍ថា មានគេស្រឡាញ់វា លុះពេលធំពេញវ័យ គេក៏អាចផ្តល់នូវក្តីស្រឡាញ់នោះដល់អ្នកដទៃវិញដែរ។
- ឪពុកក៏មានសារៈសំខាន់ចំពោះកូនដូចម្តាយដែរ។ ឪពុកត្រូវចំណាយពេលវេលាខ្លះដើម្បីទំនាក់ទំនងល្អក្នុងការលេង និងការនិយាយជាមួយកូនៗរបស់គេ។
- ទារកចូលចិត្តក្រឡេកមើលវត្ថុដែលគួរឱ្យចាប់អារម្មណ៍។ ដូចនេះមនុស្សធំត្រូវផ្តល់វត្ថុផ្សេងៗដែលមានរំលេចដោយពណ៌ឱ្យគេបានប៉ះនឹងមើល ដើម្បីអភិវឌ្ឍភ្នែក និងខួរក្បាលរបស់គេ។
- កុមារមានការលូតលាស់ប្រាជ្ញា នៅពេលដែលមានការលើកទឹកចិត្តឱ្យមានគំនិតច្នៃប្រឌិត និងរៀនសូត្រ។
- កុមារដែលទទួលនូវចំណងផ្លូវចិត្តល្អ និងមានការស្រឡាញ់ច្រើនអាចនឹងក្លាយទៅជាមនុស្សឆ្លាតពេលពេញវ័យ ហើយនឹងជួយអ្នកដទៃទៀតដើម្បីអភិវឌ្ឍប្រទេសរបស់គេ។

- ទាំងកុមារា និងកុមារី មានតម្រូវការនៃក្តីស្រឡាញ់ដូចៗគ្នា។
- កុមារត្រូវការលេងនៅក្នុងបរិស្ថានមានសុវត្ថិភាព។ កុមារកម្ពុជាជាច្រើនទទួលគ្រោះថ្នាក់ជារៀងរាល់ថ្ងៃ មុតនឹងវត្ថុស្រួច ពុលនឹងសារធាតុពុល រលាកភ្លើង ធ្លាក់/ដួល លង់ទឹក សត្វខាំ និងឆក់ខ្សែភ្លើង។
- ការវាយ សំឡុត ឬធ្វើឱ្យកុមារភ័យខ្លាច អាចធ្វើឱ្យមិនសប្បាយចិត្តនឹងបង្កបញ្ហានៅពេលគេធំឡើង។
- ប្រសិនបើកូនរបស់អ្នកលូតលាស់ ឬមានសកម្មភាពមិនធម្មតា វាជាការសំខាន់ណាស់ដែលត្រូវស្វែងរកដំបូន្មានពីគ្រូមតេយ្យ/បឋម អ្នកធ្វើការសហគមន៍ គិលានុប្បដ្ឋាក/យិកា ឬវេជ្ជបណ្ឌិតភ្លាមៗ ព្រោះអាចការពារពីពិការភាពនាពេលអនាគត។

**សង្ខេបមេរៀន:** សួរទៅសិក្ខាកាមថា តើពួកគេយល់ស្របជាមួយគំនិតទាំងឡាយដែលបានបង្ហាញនៅក្នុងសកម្មភាពនេះឬទេ? បើយល់ស្របហេតុអ្វី? បើមិនយល់ស្របហេតុអ្វី?

**សារគន្លឹះ:**

**កុមារលូតលាស់ជាបន្តបន្ទាប់ និងពេញលេញ នៅពេលដែលគេ:**

- ទទួលបាននូវសេចក្តីស្រឡាញ់ និងថែទាំដោយយកចិត្តទុកដាក់
- មានអ្នកស្តាប់នូវអ្វីៗដែលកុមារនិយាយ និងឆ្លើយតបមកគេវិញ
- មានឱកាសធ្វើចលនា និងហាត់ពត់ខ្លួនប្រាណ
- មានឱកាសលេងដោយសុវត្ថិភាព និងរកឃើញនូវអ្វីៗដែលថ្មីក្នុងបរិស្ថានមានសុវត្ថិភាព
- អាចមានទំនាក់ទំនងជាមួយអ្នកដទៃ
- ទទួលការសរសើរ និងលើកទឹកចិត្ត

**មាតាបិតា និងអ្នកថែទាំទាំងឡាយ ជាមនុស្សសំខាន់បំផុតដល់ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។**

**គួរទុកឱ្យកូនវិវត្តន៍តាមវាសនា ឬជំរុញឱ្យប្រសើរឡើង?**

**ការវាយតម្លៃ:** សំណួរសម្រាប់វាយតម្លៃមេរៀន

**ឯកសារយោង:**


១. *គម្រោងកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកស្ម័គ្រចិត្តសុខភាពភូមិស្តីពីទម្លាប់អនុវត្តរបស់គ្រួសារនៃ សមាហរណកម្ម ការទទួលបន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ, ៣ជ្រោង ខែមិថុនា ឆ្នាំ២០០៤ ម៉ូឌុលទី ៦ មេរៀនទី២*

២. *សន្លឹកផ្ទាត់ និង ខិត្តប័ណ្ណ របស់ក្រសួងអប់រំ យុវជន និង កីឡា*

**មេរៀនទី ៣: ដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារ** **រយៈពេល: ៣ម៉ោង ៣០នាទី**

**វត្ថុបំណងនៃការសិក្សា:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាច :

១. រៀបរាប់អំពីដំណាក់កាលនៃការលូតលាស់ដោយសុវត្ថិភាពរបស់កុមារ និងវិធីនានាដើម្បីជួយដល់ការលូតលាស់របស់កុមារ ទៅតាមវ័យ

២. ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវសន្លឹកផ្ទាត់គន្លឹះ១២យ៉ាងសម្រាប់សុខភាពគ្រួសារ និងប័ណ្ណជំនួយការងារ

**សម្ភារៈជំនួយបង្រៀន:**

- រូបភាពរបស់កុមារតាមវ័យ
- សន្លឹកផ្ទាត់គន្លឹះ ១២យ៉ាងសម្រាប់សុខភាពគ្រួសារ (ទំព័រទី ៧)
- ក្រដាសផ្ទាំងធំ ហ្វឺតខៀវ និងក្រហម និងស្កុតស្ទិត

**វិធីសាស្ត្របង្រៀន:**

- ការបំផុសគំនិតថ្មីៗ
- ការពិភាក្សាក្រុមធំ

**ជំហានសកម្មភាព:**

**បង្ហាញពីវត្ថុបំណងរួម**

**សេចក្តីផ្តើម** (ធ្វើការសន្ទនាបើអាចធ្វើបាន): ឥឡូវនេះ យើងបានសិក្សារួចហើយអំពីហេតុអ្វីបានជាការអភិវឌ្ឍផ្លូវចិត្ត-សង្គមមានសារៈសំខាន់ ចូរពិភាក្សាពីវត្ថុអ្វីខ្លះដែលទារកចូលចិត្តលេងនៅតាមអាយុផ្សេងៗគ្នា។ ប្រហែលជាអ្នកបានដឹងរួចហើយ ទារកមានការលូតលាស់ជាដំណាក់កាលៗដែលពួកគេ អាចធ្វើអ្វីមួយពិតប្រាកដ បានស្របទៅនឹងការលូតលាស់របស់គេ។ ពួកគេអាចធ្វើអ្វីៗកាន់តែច្រើនឡើងៗ នៅរៀងរាល់ ២-៣ខែ។

ប្រសិនបើទារក ឬកូនរបស់ពួកគេលូតលាស់មិនធម្មតា ការស្វែងរកជំនួយទានពីគ្រូមតេយ្យ អ្នកធ្វើការសុខភាពសហគមន៍ គិលានុប្បដ្ឋាក/យិកា ឬវេជ្ជបណ្ឌិតភ្លាមៗ មានសារៈសំខាន់ណាស់ ដែលនេះអាចការពារពីពិការភាពនៅអនាគត។ មុនចាប់ផ្តើម ចូរសួរសិក្ខាកាមថា តើមានសំណួរអ្វីឬទេ?

**វត្ថុបំណងទី១: រៀបរាប់អំពីដំណាក់កាលនៃការលូតលាស់របស់កុមារ និងវិធីនានា ដើម្បីជួយដល់ការលូតលាស់របស់កុមារទៅតាមអាយុ**

- **ពិភាក្សាក្រុមតូច**

១. អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជាបីក្រុម។

- ក្រុមនិមួយៗ ត្រូវពិភាក្សាទៅតាម**ក្រុមអាយុ:**
  - ក្រុមទី១: ក្រុមអាយុ ០-១ខែ ១-៣ខែ និង ៣-៦ខែ
  - ក្រុមទី២: អាយុ ៦-៩ខែ និង ៩-១២ខែ
  - ក្រុមទី៣: អាយុ ១-២ឆ្នាំ និង អាយុ ២-៣ឆ្នាំ
- ក្រុមនីមួយៗត្រូវពិភាក្សាអំពី **អ្វីដែលជាសកម្មភាពជួយជំរុញកូន** និង**អ្វីដែលជាដំបូន្មានសម្រាប់មាតាបិតា**។
- ក្រុមនិមួយៗ ពិភាក្សា២០នាទី និងបង្ហាញចម្លើយ ១៥នាទី។

២. អ្នកសម្របសម្រួលសរុបព្រមទាំងពន្យល់ថា កុមារចាប់ផ្តើមរៀន និងលូតលាស់យ៉ាងឆាប់រហ័ស បន្ទាប់ពីកើត ហើយឪពុកម្តាយមានតួនាទីសំខាន់ណាស់ក្នុងការជួយពួកគេឱ្យបានទាន់ពេលវេលា ព្រមទាំងបង្ហាញពីការវិវត្តន៍របស់កូនពីមួយខែទៅមួយខែ និងអ្វីដែលឪពុកម្តាយអាចជួយជំរុញកូនរបស់គាត់ឱ្យមានការអភិវឌ្ឍពេញលេញ។ ជាពិសេសពន្យល់ថា ប្រសិនបើទារក/កុមារលូតលាស់ឬមានសកម្មភាពមិនប្រក្រតី ការស្វែងរកដំបូន្មានពីគ្រូមត្តេយ្យ/បឋម អ្នកធ្វើការសុខភាពសហគមន៍ គិលានុប្បដ្ឋាក/យិកា ឬវេជ្ជបណ្ឌិតភ្លាមៗ ដើម្បីពិគ្រោះយោបល់បានទាន់ពេលវេលា អាចការពារពីពិការភាព។

៣. អ្នកសម្របសម្រួលបង្ហាញពីចម្លើយដូចខាងក្រោម:

**ទារក/កុមារអាយុ ០-១ខែ (ពីកើតដល់១ខែ):**

*ទារក/កុមារអាច (សរសេរដោយហ្វឺតខៀវ):*

- មើលឃើញ
- ស្តាប់ឮ
- មានអារម្មណ៍ដឹងនៅពេលប៉ះពាល់



*សកម្មភាពជួយជំរុញ (សរសេរដោយហ្វឺតក្រហម):*

- ដាក់វត្ថុដែលមានពណ៌ស្រស់ៗតែមានសុវត្ថិភាពព្យួរនៅលើអង្រឹង ឬគ្រែរបស់កុមារ ដូចនេះវាអាចមើលឃើញបាន
- បញ្ចេញសំលេងនៅក្បែរកុមារ ដូច្នេះកុមារអាចស្តាប់ឮ
- ផ្តល់នូវសេចក្តីស្រឡាញ់ និងការថ្នាក់ថ្នមដល់កុមារ
- និយាយ ញញឹម ច្រៀងបំពេរ ឱ្យក្មេងស្តាប់

*ដំបូន្មានសុខភាព និងសុវត្ថិភាពសម្រាប់មាតាបិតា (សរសេរដោយហ្វីតខ្មៅ):*

- ចូរបំបៅកូនភ្លាមដោយទឹកដោះម្ដាយក្នុងអំឡុងពេល១ម៉ោងក្រោយសំរាល
- ចូរស្រលាញ់ទារកគ្រប់ពេលដែលអ្នកលើកបី ។ ចូរកុំទុកទារកឱ្យនៅម្នាក់ឯងដោយគ្មានអ្នកមើល ។
- ចូរដាក់កូនគេងក្នុងមុងទាំងពេលយប់និងពេលថ្ងៃ
- ចូរព្យាយាមដាក់កូនឱ្យគេងលើផ្ទៃរាប ឬកុំដាក់នៅទីកន្លែងដែលក្ដោបតឹងពេកទេ ដើម្បីចៀសវាងការកោងខ្នង
- ត្រូវមានខ្នើយកើយឱ្យបានត្រឹមត្រូវ ដាក់ក្បាលត្រង់តាមដងខ្លួន និងឧស្សាហ៍ប្រែក្បាល ម្ដងផ្អៀងទៅស្ដាំ ម្ដងផ្អៀងទៅឆ្វេង ដើម្បីរក្សាទម្រង់ក្បាលកូនឱ្យបានល្អ
- ពេលងូតទឹកត្រូវប្រុងប្រយ័ត្នទឹកចូលត្រចៀកកូន ងូតទឹករួចត្រូវយកសំឡី/កំណាត់ទន់មកជូតរន្ធត្រចៀក
- ចូរនាំកូនទៅចុះសំបុត្រកំណើត ។

## ទារក/កុមារអាយុ ១-៣ខែ:

*ទារក/កុមារអាច (សរសេរដោយហ្វីតខៀវ):*




- ងើបក្បាល ព្យាយាមក្រឡាប់
- ភ្នែកតាមមើលវត្ថុព្យួរដែលមានចលនា
- ដៃព្យាយាមចាប់ ក្ដាប់ ឬកាន់វត្ថុ
- ញញឹមតបមករកអ្នក
- ចំណាំម្ដាយ និងស្គាល់សំលេងម្ដាយ

*សកម្មភាពជំរុញលើកទឹកចិត្ត (សរសេរដោយហ្វីតក្រហម):*

- ដាក់វត្ថុដែលមានពណ៌ចម្រុះដែលមានសុវត្ថិភាពនៅលើគ្រែ ឬអង្រឹងរបស់កុមារ ដូចនេះវាអាចមើលឃើញបាន
- បញ្ចេញសំលេងនៅក្បែរកុមារ ដូច្នេះកុមារអាចស្ដាប់ឮ
- ឱ្យទារកលាដៃត្រាប់តាមល្បែង (ចាប់ចាប)
- ផ្ដល់នូវសេចក្ដីស្រឡាញ់ និងការថ្នាក់ថ្នមដល់កុមារ (និយាយ ញញឹម និងច្រៀង/បំពេ ឱ្យកុមារស្ដាប់)
- ផ្ដល់ប្រដាប់ប្រដាលេងសាមញ្ញៗដែលមានពណ៌ចំរុះ និងមានសុវត្ថិភាពដល់កុមារ

*ដំបូន្មានសុខភាព និងសុវត្ថិភាពសម្រាប់មាតាបិតា (សរសេរដោយហ្វីតខ្មៅ):*

- ត្រូវលាងដោះមុននឹងឱ្យកូនបៅ

- ចូរកុំទុកទារកឱ្យនៅម្នាក់ឯង ដោយគ្មានអ្នកមើល
- ត្រូវប្រយ័ត្នកុំឱ្យមនុស្សជក់បារីបី/ពរទារក ឬទុកទារកនៅក្បែរផ្សែងបារី/ផ្សែងផ្សេងៗ។

**ទារក/កុមារអាយុ ៣-៦ខែ**

*ទារក/កុមារអាច (សរសេរដោយហ្វីតខៀវ):*



- ក្រឡាប់
- អង្គុយដោយមានគេជួយទប់
-ចេះទាញយកវត្ថុផ្សេងៗដែលនៅក្បែរខ្លួន
- បន្លឺសំលេង កកែរកករ ជួនកាលសើចញ្ញៗ
- ស្គាល់អ្នកនៅជុំវិញ (ពិសេសក្នុងគ្រួសារ) និងវត្ថុផ្សេងៗ

*សកម្មភាពជំរុញលើកទឹកចិត្ត (សរសេរដោយហ្វីតក្រហម):*

- ដាក់កុមារឱ្យដេកផ្ងារ ហើយផ្សៀងម្តងទៅឆ្វេង ម្តងទៅស្តាំ
- ដាក់កុមារនៅលើកំរាលក្រណាត់ស្អាត ហើយកុមារអាចធ្វើចលនាដៃ-ជើង
- បង្កើតភាពស្រឡាញ់ និងថ្នាក់ថ្នមចំពោះកុមារ
- និយាយលេង និងច្រៀងបំពេរ ឱ្យកុមារស្តាប់

*ដំបូន្មានសុខភាព និងសុវត្ថិភាពសម្រាប់មាតាបិតា (សរសេរដោយហ្វីតខ្មៅ):*

- មិនត្រូវទុកទារកឱ្យនៅតែម្នាក់ឯងនៅទីខ្ពស់ (គ្រែ តុ កៅអី...) ពីព្រោះអាចធ្លាក់។
- កុំទុកកូននៅក្បែរចង្ក្រានដែលកំពុងមានភ្លើង កំសៀវទឹកក្តៅ ឬកំប៉ុងថ្នាំពុល ។ល។

**ទារក/កុមារអាយុ ៦-៩ខែ:**

*ទារក/កុមារអាច (សរសេរដោយហ្វីតខៀវ):*



- ស្រែកឮសំលេងខ្លាំងៗ
- អង្គុយដោយខ្លួនឯង
- ចេះលូន ឬវារបាន
- និយាយបានមួយ ឬពីរម៉ាត់ (ប៉ា ម៉ាក់ ពុក...)
- ផ្ទេរវត្ថុផ្សេងៗពីដៃម្ខាង ទៅដៃម្ខាងទៀត
- យំនៅពេលឃ្លាន ឈឺ និងមានអារម្មណ៍/អាការៈមិនសុខស្រួល
- យំតាមឪពុកម្តាយ ឬអ្នកថែទាំ
- ខ្លាចមនុស្សដែលមិនស្គាល់

*សកម្មភាពជំរុញលើកទឹកចិត្ត (សរសេរដោយហ្វីតក្រហម):*

- លេងវត្ថុផ្សេងៗជាមួយកុមារ ដូចជា បង្ហាញ និងដាក់ឈ្មោះវត្ថុផ្សេងៗ លាក់ ឬផ្លាស់ទីកន្លែងវត្ថុផ្សេងៗ ញាក់មុខ ឬទះដៃ
- បង្កើនភាពស្រឡាញ់ និងថ្នាក់ថ្នមចំពោះកុមារ
- និយាយ ញញឹម និងច្រៀងបំពេរ ឱ្យកុមារស្តាប់

*ដំបូន្មានសុខភាព និងសុវត្ថិភាពសម្រាប់មាតាបិតា (សរសេរដោយហ្វុីតខ្មៅ):*

- ចូររៀបចំទុកដាក់វត្ថុដែលនាំឱ្យមានគ្រោះថ្នាក់ដល់កូនដូចជា សារធាតុពុល ថ្នាំពេទ្យ វត្ថុមុតស្រួច ។ល។
- ត្រូវពិនិត្យតាមដានកូនជាប្រចាំ ខ្លាចកូនរើសយកវត្ថុមកដាក់ក្នុងមាត់ (គ្រាប់គ្រួស ធញ្ញជាតិ...) ជាពិសេស ថង់ប្លាស្ទិក ប៉េងប៉ោង...ដែលបណ្តាលឱ្យស្លាក់។

## ទារក/កុមារអាយុ ៩-១២ខែ:

*កុមារអាច (សរសេរដោយហ្វុីតខៀវ):*

- ចាប់ផ្តើមកាន់របស់ផ្សេងៗ ដោយប្រើម្រាមដៃ និងមេដៃ។
- ចាប់ផ្តើមតោងឈរ និងរៀនដើរដោយមានជំនួយ
- ធ្វើត្រាប់តាម
- និយាយពាក្យងាយៗ ពីរឬបីម៉ាត់
- ស្គាល់ឈ្មោះខ្លួនឯង និងអ្នកជុំវិញ



*សកម្មភាពជំរុញលើកទឹកចិត្ត (សរសេរដោយហ្វុីតក្រហម):*

- ផ្តល់ឱកាសឱ្យទារក/កុមារបានលេងជាមួយកុមារដទៃទៀត ក្នុងបរិស្ថានមានសុវត្ថិភាព
- ឱ្យប្រដាប់ប្រដាសាមញ្ញៗ និងមានសុវត្ថិភាពទៅកូនសម្រាប់លេង ដើម្បីហ្វឹកហាត់ឱ្យចេះចាប់ កាន់ រើសឡើង និងទម្លាក់វត្ថុនានា
- បង្រៀនកូនឱ្យប្រាប់ឈ្មោះវត្ថុផ្សេងៗ
- បង្កើនភាពស្រឡាញ់ និងថ្នាក់ថ្នមចំពោះកុមារ
- សរសើរ និងលើកទឹកចិត្តកុមារ
- និយាយ ញញឹម និងច្រៀងរកក្មេង

*ដំបូន្មានសុខភាព និងសុវត្ថិភាពសម្រាប់មាតាបិតា (សរសេរដោយហ្វុីតខ្មៅ):*

- ចូររៀបចំទុកដាក់វត្ថុដែលនាំឱ្យមានគ្រោះថ្នាក់ដល់កូនដូចជា ចង្កៀង កៅអីទឹក ខ្សែយោលចុះឡើង វត្ថុដែលអាចតោងបាន...ព្រោះនៅពេលនោះ កូនអ្នកនឹងចាប់ផ្តើមរៀនតោងឈរ ឬកាន់/ទាញវត្ថុ

នានា

- ចូរជួយកូនអ្នក ក្នុងការរៀនតោងឈរ/ដើរ ។

**កុមារអាយុ ១-២ឆ្នាំ:**



*កុមារអាច (សរសេរដោយហ្វីតខៀវ):*

- ចេះដើរ និងរត់ ចេះនិយាយពាក្យ ខ្លីៗ ស្គាល់រូបភាពងាយៗ
- ចេះធ្វើត្រាប់តាម
- ចូលចិត្តលេង និងទំនាក់ទំនងជាមួយកុមារដទៃទៀត ឬមនុស្សចាស់
- ប្រាប់ឈ្មោះផ្នែកនានានៃរាងកាយ
- ចូលចិត្តស្លៀកពាក់ ឬដោះសំលៀកបំពាក់ដោយខ្លួនឯង
- ចូលចិត្តឆ្ងល់ ចង់ដឹង និងសួរច្រើន
- យល់ពីពាក្យមនុស្សធំនិយាយប្រាប់

*សកម្មភាពជំរុញលើកទឹកចិត្ត (សរសេរដោយហ្វីតក្រហម):*

- និយាយជាមួយកុមារឱ្យបានច្រើន និងនិទានរឿងឱ្យគេស្ដាប់
- ផ្ដល់ឱកាសឱ្យកូនបានលេងជាមួយកុមារដទៃទៀតក្នុងបរិស្ថានមានសុវត្ថិភាព
- បង្ហាត់ឱ្យកុមារចេះស្លៀកពាក់ លាងដៃ ញ៉ាំបាយ ... ដោយខ្លួនឯង
- បង្រៀនកុមារពីរបៀបបន្ទោរបង់
- ឱ្យប្រដាប់ប្រដាសាមញ្ញៗ និងមានសុវត្ថិភាពទៅកុមារសម្រាប់លេង ដើម្បីហ្វឹកហាត់កូនឱ្យចាប់កាន់ រើសឡើង និងទម្លាក់វត្ថុនានា
- ប្រាប់ឈ្មោះអាហារ និងវត្ថុប្រើប្រាស់ផ្សេងៗក្នុងផ្ទះដល់កុមារ
- បង្កើនភាពស្រឡាញ់ និងថ្នាក់ថ្នមចំពោះកុមារ
- សរសើរ និងលើកទឹកចិត្តកុមារ

*ដំបូន្មានសុខភាព និងសុវត្ថិភាពសម្រាប់មាតាបិតា (សរសេរដោយហ្វីតខ្មៅ):*

- ចូរថែរក្សាអនាម័យឱ្យកូនជាប្រចាំ ដូចជា លាងដៃ ងូតទឹក ផ្លាស់សំលៀកបំពាក់
- ចូរផ្ដល់អាហារមានជីវជាតិឱ្យបានគ្រប់គ្រាន់ និងចៀសវាងអាហារដែលអាចឱ្យកូនស្លាក់
- ចូរទុកដាក់ថ្នាំពេទ្យ សារជាតិពុល ឬវត្ថុដែលអាចរលាក នៅឆ្ងាយពីដៃកូន
- ចូរប្រុងប្រយ័ត្ននិងតាមដានជាប្រចាំ ដើម្បីចៀសផុតពីគ្រោះថ្នាក់ដោយប្រការផ្សេងៗដូចជា ទុក

កូននៅតែម្នាក់ឯង ក្បែរស្រះទឹក ធុងដាក់ទឹក ប្រឡាយ អណ្តូង បន្ទប់ទឹក ឧបករណ៍អគ្គិសនី ចង្ក្រាន និងទឹកក្តៅ...។

**កុមារអាយុ ២-៣ឆ្នាំ:**

*កុមារអាច (សរសេរដោយហ្វឹតខៀវ):*



- រត់ លោត ឡើងកាំជណ្តើរ ឱនចុះ ងើបឡើង ( នេះជាសកម្មភាពដែលមិនមានគ្រោះថ្នាក់ដល់កុមារ)
- លួតលាស់ខាងភាសាឆាប់រហ័ស ដោយប្រើប្រយោគខ្លីៗ
- ចូលចិត្តធ្វើអ្វីដោយខ្លួនឯង
- ចូលចិត្តលេង និងទំនាក់ទំនងជាមួយកុមារដទៃទៀត ឬមនុស្សចាស់
- ប្រាប់ឈ្មោះផ្នែកនានានៃរាងកាយ និងប្រាប់ឈ្មោះរូបភាពងាយៗក្នុងសៀវភៅ
- ចូលចិត្តស្លៀកពាក់ ឬដោះសំលៀកបំពាក់ដោយខ្លួនឯង
- ចូលចិត្តឆ្ងល់ ចង់ដឹង និងសួរច្រើន
- ចេះបង្ហាញពីអារម្មណ៍សប្បាយ ខឹង ស្រឡាញ់

*សកម្មភាពជំរុញលើកទឹកចិត្ត (សរសេរដោយហ្វឹតក្រហម):*

- បង្ហាត់ឱ្យកូនចេះស្លៀកពាក់ ពាក់ស្បែកជើងខ្លួនឯង
- បង្រៀនពីអនាម័យ ភាពស្អាតនៃខ្លួនប្រាណ
- និទានរឿងឱ្យកុមារស្តាប់ បង្ហាញរូបភាពផ្សេងៗ និងផ្តល់ឱកាសឱ្យកូនបានគូសវាសដោយប្រើចលនាដៃ
- ផ្តល់ឱកាសឱ្យកូនបានលេងជាមួយកុមារដទៃទៀតក្នុងបរិស្ថានមានសុវត្ថិភាព
- បង្ហាត់ឱ្យកុមារចេះស្លៀកពាក់ លាងដៃ ញ៉ាំបាយ ... ដោយខ្លួនឯង
- បង្រៀនកុមារពីរបៀបបន្ទោបង់
- បង្កើនភាពស្រឡាញ់ និងថ្នាក់ថ្នម សរសើរ និងលើកទឹកចិត្តដល់កុមារ

*ដំបូន្មានសុខភាព និងសុវត្ថិភាពសម្រាប់មាតាបិតា (សរសេរដោយហ្វឹតខ្មៅ):*

- ចូរផ្តល់អាហារដែលមានជីវជាតិគ្រប់គ្រាន់ និងមានអនាម័យល្អដល់កូន
- ចូររក្សាបរិស្ថានស្អាត អនាម័យខ្លួនប្រាណ និងមានសម្លៀកបំពាក់ស្អាតជាប្រចាំ

- ចូរណែនាំកូនឱ្យនៅឆ្ងាយពីកន្លែងខ្ពស់ ឬធ្លាក់ក្នុងទឹក (ទន្លេ បឹង ស្ទឹង ស្រះ តំបន់លិចទឹក) ប៉ះពាល់សំភារៈអគ្គីសនី សារធាតុពុល លេងវត្ថុមុតស្រួច ស្លាក់ សត្វអាចខាំ ឬបង្កជម្ងឺ
- ត្រូវធ្វើរបង/គម្របដើម្បីការពារ ស្រះទឹក ត្រពាំង អណ្តូង...
- ចូរណែនាំកូន កុំឱ្យលេងនៅក្បែរផ្លូវថ្នល់ ដែលអាចបណ្តាលឱ្យគ្រោះថ្នាក់។

១. ផ្តល់ឱកាសឱ្យសិក្ខាកាមសួរសំណួរ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់ថា ពេលខ្លះការលូតលាស់របស់កុមារមានការយឺតយ៉ាវ ឬលឿនជាងអ្វីដែលមានបញ្ជាក់នៅក្នុងការបង្ហាញនេះ ប៉ុន្តែបើសិនវាកំពង់លូត-លាស់ខុសធម្មតា មាតាបិតាអាចស្វែងរកដំបូន្មានពីគ្រូមតេយ្យ ឬនាំកូនទៅជួបអ្នកធ្វើការសុខភាព សហ-គមន៍ គិលានុប្បដ្ឋាក វេជ្ជបណ្ឌិតភ្លាម ជាពិសេសបើសិនកូនៈ

- ពិបាកហូបអាហារ
- ពិបាកបញ្ចេញសំលេង
- ខ្សោយអវៈយវៈ ឬមានអវៈយវៈខុសពីធម្មតា ឬមិនអាចកំរើកដៃ ឬជើង
- មានក្បាលធំខុសពីធម្មតា ឬមានឆែបមាត់
- ភ្នែកហើម ឬប៉ោង ស្រលៀង ឬហាក់ខុសពីធម្មតា
- យំគ្រប់ពេលដោយពិបាកលួង
- ហាក់ដូចជាមិនអាចនិយាយ គ្មានភាពស្និទស្នាល ឬហាក់ដូចជាភ័យខ្លាចចំពោះក្មេងដទៃទៀត និងមនុស្សចាស់។
- វាយ ខាំ និងរុញច្រានក្មេងដទៃ ឬមានសកម្មភាពឯកកោ មិនចង់ចូលក្នុងចំណោមក្មេងដទៃ។

## វត្ថុបំណងទី ២: ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវសន្លឹកផ្ទាត់គន្លឹះ១២យ៉ាងសម្រាប់សុខភាពគ្រួសារ និងប័ណ្ណជំនួយការងារ (២០នាទី)

➢ **បង្ហាញសន្លឹកផ្ទាត់គន្លឹះ១២យ៉ាងសម្រាប់សុខភាពគ្រួសារ និងប័ណ្ណជំនួយការងារ**

១. ឱ្យសិក្ខាកាមពិនិត្យមើលទំព័រ សន្លឹកផ្ទាត់គន្លឹះ១២យ៉ាងសម្រាប់សុខភាពគ្រួសារ និងប័ណ្ណជំនួយការងារសម្រាប់ម៉ូឌុលនេះរយៈពេល៥នាទី។ ការធ្វើបែបនេះ ដើម្បីឱ្យពួកគេដឹងអំពីអ្វីខ្លះដែលមាននៅលើទំព័រសន្លឹកផ្ទាត់ និងប័ណ្ណជំនួយការងារនោះ ព្រមទាំងជួយឱ្យពួកគេយល់ពីសារនៅក្នុងនោះ។

២. រៀបចំសិក្ខាកាមជាក្រុមហើយស្នើឱ្យពួកគេអនុវត្តការប្រើទំព័រសន្លឹកផ្ទាត់ និងប័ណ្ណការងារទាំងនោះ។ សុំឱ្យសមាជិកណាម្នាក់ក្នុងក្រុមជាអ្នកអនុវត្ត ហើយអ្នកដទៃទៀតសង្កេត ហើយបន្ទាប់មកផ្តល់យោបល់។

៣. មុននឹងបញ្ចប់ការពិភាក្សាក្រុម អ្នកសម្របសម្រួលសុំឱ្យសិក្ខាកាមម្នាក់ឡើងបង្ហាញរយៈពេល៥នាទី ជា "ក្រុមទ្រទ្រង់សុខភាពភូមិ" ដល់ "ម្តាយ" ម្នាក់នៅចំពោះមុខក្រុមធំទាំងមូល ដោយប្រើប្រាស់សន្លឹកផ្ទាត់ ឬប័ណ្ណជំនួយការងារ។ ឱ្យអ្នកទ្រទ្រង់សុខភាពភូមិ បង្ហាញអំពីប្រធានបទ និងពន្យល់ហេតុអ្វីបានជាប្រធានបទនោះសំខាន់ បន្ទាប់មកស្នើឱ្យម្តាយធ្វើកិច្ចការមួយ ក្រោយពីបានទទួលព័ត៌មានពីអ្នកទ្រទ្រង់សុខភាពភូមិ ដើម្បីលើកកម្ពស់សុខភាពរបស់កូនគាត់។

៤. ក្រោយពីបង្ហាញចប់ ក្រុមទាំងមូលគួរផ្តល់ព័ត៌មានត្រឡប់ អំពីអ្វីដែលគេបានឃើញអ្វីខ្លះដែលអ្នកទ្រទ្រង់សុខភាពភូមិធ្វើបានល្អ ឬគួរកែលំអ ព្រមទាំងតើពួកគេមានផែនការធ្វើអ្វីខ្លះនៅពេលពួកគេវិលត្រឡប់ទៅភូមិរបស់គេវិញ។

៥. សួរសិក្ខាកាម តើមានសំណួរអ្វីឬទេ។

**សង្ខេបមេរៀន:** អ្នកសម្របសម្រួលធ្វើការសង្ខេបខ្លឹមសារមេរៀនឡើងវិញ។

**សារគន្លឹះអំពីសន្លឹកផ្ទាត់គន្លឹះទាំង១២សំរាប់សុខភាពគ្រួសារ និងសំភារៈអប់រំ: អ្នកសំរបសំរួល បង្ហាញទំព័រទី៧នៃសន្លឹកផ្ទាត់គន្លឹះទាំង១២សំរាប់សុខភាពគ្រួសារ សំភារៈអប់រំ និងសារព្រម ទាំងសារនិងរូបភាពដល់ក្រុមទាំងមូល។**

---

ការលូតលាស់របស់កុមារមានសារៈសំខាន់ណាស់ ឪពុកម្តាយត្រូវដឹងពីការលូតលាស់របស់កុមារ តាមអាយុ (វ័យ) ខាងក្រោមនេះ:

- អាយុ ០-១ ខែ : អាចមើលឃើញ ស្តាប់ឮ មានអារម្មណ៍ដឹងនៅពេលប៉ះពាល់ ញញឹមតប
- អាយុ ១-៣ ខែ : ងើបក្បាល ព្យាយាមក្រឡាប់ ភ្នែកតាមមើលវត្ថុព្យួរដែលមានចលនា
- អាយុ ៣-៦ ខែ : ចេះក្រឡាប់ អង្គុយដោយមានគេជួយទប់
- អាយុ ៦-៩ ខែ : អង្គុយដោយខ្លួនឯង ចេះលូន ឬវារបាន និយាយបានមួយ ឬពីរម៉ាត់
- អាយុ ៩-១២ ខែ : ចាប់ផ្តើមកាន់របស់ផ្សេងៗដោយប្រើម្រាមដៃ និងមេដៃ ចាប់ផ្តើមតោងឈរ...
- អាយុ ១-២ ឆ្នាំ : ដើរ និងរត់ ចេះនិយាយពាក្យខ្លីៗ ស្គាល់រូបភាពងាយៗ ចេះត្រាប់តាមនុស្សធំ
- អាយុ ២-៣ ឆ្នាំ : រត់ លោត ឡើងនិងចុះកាំជណ្តើរ លូតលាស់ខាងភាសាយ៉ាងរហ័ស
- វាយ ខាំ និងរុញច្រានក្មេងផ្សេងៗជាច្រើន ឬមានអាកប្បកិរិយាឃ្លាតឆ្ងាយ។

---

**ការវាយតម្លៃ:** រៀបចំសំណួរសម្រាប់វាយតម្លៃ

**ឯកសារយោង:**


១- *គម្រោងកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកស្ម័គ្រចិត្តសុខភាពភូមិស្តីពីទម្លាប់អនុវត្តរបស់គ្រួសារនៃសមាហរណកម្មការទទួលបន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ, ពង្រាង ខែមិថុនា ឆ្នាំ២០០៤ ម៉ូឌុល ៦ មេរៀនទី៣*

២- *សន្លឹកផ្ទាត់ ឆ្នាំ ២០០៧:* តើឪពុកម្តាយគួរធ្វើអ្វីខ្លះដើម្បីជួយការអភិវឌ្ឍកូន តាំងពីនៅក្នុងផ្ទៃ រហូតដល់អាយុបីឆ្នាំ *ក្រសួងអប់រំ យុវជន និង កីឡា*

# មេរៀនទី ៤: ការបង្ហាញពីសេចក្តីស្រឡាញ់ រយៈពេល: ១ម៉ោង

**វត្ថុបំណងនៃការសិក្សា:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាច :

១. រៀបរាប់ពីវិធីផ្សេងៗដើម្បីបង្ហាញសេចក្តីស្រឡាញ់នៅក្នុងគ្រួសារ ។

**សម្ភារៈជំនួយបង្រៀន:**

- ក្រដាស់ផ្ទាំងធំពីរសន្លឹកដោយមានសរសេរៈ "វិធីល្អដើម្បីបង្ហាញសេចក្តីស្រឡាញ់នៅក្នុងគ្រួសារ" និង "វិធីមិនល្អដែលប៉ះពាល់ដល់សេចក្តីស្រឡាញ់នៅក្នុងគ្រួសារ"
- ហ្វឺតសម្រាប់សរសេរ ស្កុតស្ទិត

**វិធីសាស្រ្តបង្រៀន:**

- សកម្មភាពជាក្រុម
- ការពិភាក្សាជាក្រុមតូច

**ជំហានសកម្មភាព:**

**បង្ហាញពីវត្ថុបំណងរួម:**

**សេចក្តីផ្តើម:** អ្នកសម្របសម្រួលគួរចាប់ផ្តើមដោយពន្យល់ថា ការបង្ហាញពីសេចក្តីស្រឡាញ់គឺសំខាន់ណាស់សម្រាប់ការអភិវឌ្ឍផ្លូវចិត្ត-សង្គមរបស់កុមារ ។ ការវាយ សំឡុត និងធ្វើឱ្យកូនភ័យ អាចជាអំពើអាក្រក់ដល់ការ-លូតលាស់ផ្លូវចិត្ត និងសង្គមរបស់កុមារ

**វត្ថុបំណង:** កំណត់ និងបង្ហាញពីវិធីផ្សេងៗដើម្បីបង្ហាញសេចក្តីស្រឡាញ់នៅក្នុងគ្រួសារ ។

➢ **ការពិភាក្សាក្រុម**

៤. អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជាពីរក្រុម ។ ក្រុមទីមួយនឹងប្រើក្រដាសផ្ទាំងធំដែលមានចំណងជើងថា "វិធីល្អដើម្បីបង្ហាញពីសេចក្តីស្រឡាញ់នៅក្នុងគ្រួសារ" និងមួយក្រុមទីពីរនឹងប្រើក្រដាសផ្ទាំងធំដែលមានចំណងជើងថា "វិធីមិនល្អដែលប៉ះពាល់ដល់សេចក្តីស្រឡាញ់នៅក្នុងគ្រួសារ" ។ក្រុមនីមួយៗត្រូវពិភាក្សាអំពីប្រធានបទនោះ ហើយសរសេរឧទាហរណ៍នៅលើក្រដាសផ្ទាំងធំ ។ សិក្ខាកាមមានពេល៣០នាទីសម្រាប់ការពិភាក្សា ។

៥. នៅពេលក្រុមទាំងពីរពិភាក្សាចប់ ក្រុមនីមួយៗត្រូវអានឧទាហរណ៍របស់ខ្លួនឱ្យគេស្តាប់ ។ សិក្ខាកាមដទៃទៀតអាចមានគំនិតបន្ថែមទៅលើឧទាហរណ៍នោះ ។ ផ្តល់ពេលវេលាប្រហែល ១៥នាទី ដល់ក្រុមនីមួយៗដើម្បីពន្យល់ពីទាហរណ៍របស់គេ ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់ដល់សិក្ខាកាមអំពីចំណុចទាំងឡាយខាងក្រោមដែលគ្រួសារទាំងឡាយ គួរអនុវត្តតាម ដើម្បីបង្កើតសេចក្តីស្រឡាញ់គ្រួសាររបស់គេ ។

ការបង្ហាញពីសេចក្តីស្រលាញ់ក្នុងគ្រួសារ មានៈ

- ការយកចិត្តទុកដាក់នឹងគ្នា
- ការធ្វើឱ្យសមាជិកក្នុងគ្រួសារសប្បាយចិត្ត
- ការប្រើភាសាទន់ភ្លន់ជាមួយគ្នា
- ការថែទាំគ្នាទៅវិញទៅមក
- ការលើកទឹកចិត្តដល់គ្នា
- ការស្តាប់ និងចេះណែនាំគ្នាទៅវិញទៅមក
- ការចេះយោគយល់គ្នានៅពេលសមាជិកណាម្នាក់ធ្វើខុស...



## សង្ខេបមេរៀនៈ

អ្នកសម្របសម្រួលដឹកនាំការពិភាក្សាតាមក្រុមខ្លីមួយ ដែលស្តីពីសំណួរថា តើសិក្ខាកាមមានអារម្មណ៍យ៉ាងណាអំពីឧទាហរណ៍ល្អទាំងនោះ ហើយថាតើពួកគេយល់ស្របថាឧទាហរណ៍ទាំងនេះសំខាន់សម្រាប់គ្រួសារ និងកុមារឬទេ។

**ការវាយតម្លៃៈ** អ្នកសម្របសម្រួលរៀបចំសំណួរអំពីមេរៀនសួរសិក្ខាកាម ដើម្បីវាយតម្លៃឡើងវិញ។

## ឯកសារយោងៈ

*១. គម្រោងកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកស្ម័គ្រចិត្តសុខភាពភូមិ ស្តីពីទម្លាប់អនុវត្តរបស់គ្រួសារនៃសមាហរណកម្មការទទួល បន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ, ពង្រាង ខែមិថុនា ឆ្នាំ២០០៤ ម៉ូឌុល ៦ មេរៀនទី៤*

## មេរៀនទី ៥ : ការផលិតឧបករណ៍បន្លឺសូរសម្លេង (ជម្រើស) រយៈពេល: ១៥នាទី

**វត្ថុបំណងនៃការសិក្សា:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាចៈ

១. រៀនអំពីរបៀបផលិតឧបករណ៍បន្លឺសូរសម្លេង សម្រាប់ទារកអាយុពី 0 ដល់ ១២ខែ លេង។

**សម្ភារៈជំនួយបង្រៀន:**

- សម្រាប់សិក្ខាកាមម្នាក់ៗ: សំបកដបទឹកសុទ្ធមានគម្រប( ពុំមានពណ៌ហើយថ្លា អាចមើលឃើញ)
- វត្ថុពណ៌ផ្សេងៗ ជាច្រើនដែលអាចដាក់ចូលទៅក្នុងដបបាន ដូចជា គ្រាប់ពពាយ សណ្តែកសៀង ក្រដាសពណ៌ ដែលមានពណ៌ខុសៗគ្នា។

**វិធីសាស្ត្របង្រៀន:**

- បង្ហាញពីរបៀបផលិតសម្ភារៈសម្រាប់ទារកលេង និងការអនុវត្ត

**ជំហានសកម្មភាព:**

**បង្ហាញវត្ថុបំណងរួម:**

**សេចក្តីផ្តើម:** ចូរសិក្សាអំពីរបៀបផលិតឧបករណ៍បន្លឺសូរសម្លេងរណ្តំគ្នាសម្រាប់ទារកស្តាប់។ ឧបករណ៍នេះគឺជាវត្ថុមួយដែលបង្កើតជាសូរសម្លេងនៅពេលដែលក្រឡុកវា។ ឧបករណ៍បន្លឺសូរសម្លេង សម្រាប់ទារកលេង ដ៏សាមញ្ញមួយនេះ អាចបង្កើតជាសូរសម្លេងដែលចេញជាចង្វាក់ផ្សេងៗ ដែលអាចទាក់ទាញអារម្មណ៍ បង្កើតភាពរស់រវើករបស់ទារកនៅពេលដែលគេបានស្តាប់។ វត្ថុដែលល្អបំផុតសម្រាប់ប្រើ គឺជាវត្ថុមិនធ្ងន់ នឹងអាចបង្កើតសម្លេងបានល្អ តែមិនងាយបែក មានភាពស្ងួត មិនដុះផ្សិត ឬស្អុយរលួយ និងមានពណ៌ច្រើនចម្រុះគ្នា ដើម្បីទាក់ទាញអារម្មណ៍ និងជួយអភិវឌ្ឍន៏ផ្នែកបំណិន ក្នុងការសង្កេត ការស្តាប់ និងចលករធំរបស់ទារក។ មានឧទាហរណ៍ខ្លះៗសម្រាប់បង្ហាញនៅទីនេះ ប៉ុន្តែអ្នកអាចប្រើប្រាស់សម្ភារៈផ្សេងទៀតបាន ដូចជាសំបកខ្ចៅស្អាត ឡេវអាវ...។

១. បង្ហាញវត្ថុផ្សេងៗដែលត្រូវផលិត



២. យកសំបកដបទឹកសុទ្ធមួយដែលមានទំហំតូចល្មម អាចឱ្យទារកចាប់កាន់បាន មកបកផ្លាកចេញសំអាតឱ្យស្អាត និងជូតឱ្យស្ងួតទុកមួយអន្លើ។

៣. យកគ្រាប់ធញ្ញជាតិដែលមានទំហំមិនឱ្យធំពេក ដូចជាគ្រាប់ពពាយ គ្រាប់សណ្ដែកសៀង ក្រដាសពណ៌សម្រាប់ដាក់បញ្ចូលក្នុងដប ដោយមានលាយចម្រុះ រូបរាង ទំហំ ពណ៌ ដើម្បីឱ្យទារកចាប់អារម្មណ៍ខ្លាំងក្នុងការមើល និងស្ដាប់សម្លេងដែលចេញពីឧបករណ៍នេះ។

៤. យកសំបកដបដែលសំអាតរួច មកដាក់គ្រាប់ធញ្ញជាតិ និងក្រដាសពណ៌ចូលទៅក្នុងដប រួចមួលបិទគម្របដប ឱ្យតឹងមិនអាចឱ្យទារកបើកវិញបាន( បើអាចលាបកាវក្នុងគំរបមុននឹងបិទ) ។ បន្ទាប់មក ក្រឡុកវា។



*មុននឹងឱ្យឧបករណ៍ទៅទារកលេង យើងត្រូវត្រួតពិនិត្យវាជាមុន និងប្រាកដថាមានអនាម័យ និងមានសុវត្ថិភាពដល់ទារក។ រាល់ការលេងរបស់ទារក ឪពុកម្ដាយ មនុស្សធំត្រូវនៅក្បែរគេជានិច្ច ដើម្បីសង្កេតរាល់សកម្មភាពរបស់គេ និងបញ្ចៀសគ្រោះថ្នាក់ ជាពិសេសអាចជួយ សង្គ្រោះទារកបានទាន់ពេលវេលាដែលកើតចេញពីដបបែក ឬមានគ្រាប់ផ្សេងៗដែលមាននៅក្នុងដបធ្លាក់ចេញមកក្រៅ ទារករើសមកដាក់ក្នុងមាត់របស់គេ ( អាចធ្វើឱ្យទារកស្លាក់) ។

៥. សូមសួរបើសិនមានសំណួរផ្សេងៗ

៦. អ្នកសម្របសម្រួលអាចប្រាប់ដល់សិក្ខាកាមផងដែរថា ឪពុកម្ដាយ ឬអ្នកថែទាំទារកអាចទិញប្រដាប់ក្មេងលេងដូចជា ឧបការណ៍បន្លឺសូរសម្លេងដែលមានលក់នៅលើទីផ្សារ ឱ្យទារកលេងបានផងដែរ។

**សង្ខេបមេរៀន:** អ្នកសម្របសម្រួល ស្នើឱ្យសិក្ខាកាមម្នាក់រៀបរាប់ពីរបៀបធ្វើឧបករណ៍បន្លឺសម្លេង សម្រាប់ទារកលេង។

**ការវាយតម្លៃ:** ហេតុអ្វីបានជាឧបករណ៍បន្លឺសម្លេងនេះ មានសារៈសំខាន់ចំពោះទារក?

**ឯកសារយោង:**

*១. គម្រោងកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកស្ម័គ្រចិត្តសុខភាពភូមិ ស្ដីពីទម្លាប់អនុវត្តរបស់គ្រួសារនៃសមាហរណកម្មការទទួលបន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ. ពង្រាង ខែមិថុនា ឆ្នាំ ២០០៤ ម៉ូឌុលទី៦ មេរៀនទី៥។*

## មេរៀនទី ៦: ការផលិតវត្ថុរំយោល (ជម្រើស) រយៈពេល: ៣០នាទី

**វត្ថុបំណងនៃការសិក្សា:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាចៈ

១. រៀនអំពីរបៀបផលិតរំយោល សម្រាប់ទារកអាយុពី ០ ដល់ ៦ខែ។

**សម្ភារៈជំនួយបង្រៀន:**

- សម្រាប់សិក្ខាកាមម្នាក់ៗ: បន្ទះឫស្សី/ខ្សែលួស កំទេចកំណាត់ដែលមានពណ៌ស្រស់ៗ (ក្រហម លឿង បៃតង) ខ្សែនីឡុង កន្ត្រៃ និងហ្វឹតសរសេរ។

**វិធីសាស្ត្របង្រៀន:**

- បង្ហាញពីការធ្វើប្រដាប់ប្រដាសម្រាប់ទារកលេង និងការអនុវត្ត

**ជំហានសកម្មភាព:**

សេចក្តីផ្តើម: ឥឡូវនេះ យើងនឹងសិក្សាអំពីរបៀបផលិតសម្ភារៈសម្រាប់ទារកដែលមានអាយុពី ០ ដល់ ៦ខែ វត្ថុរំយោលនេះអាចត្រូវបានចងព្យួរលើអង្រឹង ដើម្បីឱ្យទារកសម្លឹងមើល។ វត្ថុនេះអាចជួយភ្ញោចដល់ភ្នែក និងខួរក្បាលរបស់ទារក នៅពេលដែលគេបានសង្កេត។

១. បង្ហាញវត្ថុផ្សេងៗដែលត្រូវផលិត



២. យកបន្ទះឫស្សី(ឬវត្ថុដែលអាចពត់ជារង្វង់បាន)មកបិតឱ្យស្អាត ហើយពត់ជារង្វង់កងដែលមានអង្កត់ផ្ចិត ១៥០ មម (មួយតឹកកន្លះ) ហើយយកខ្សែនីឡុងរុំមុខដំណរឱ្យបានជាប់ល្អ។

៣.យកអំបោះ ឬខ្សែមកចងព្យួរពីលើអង្រឹង

៤. កាត់កំណាត់ទាំងអស់ជារាងរង្វង់មូល ដែលមានបន្ទាត់ផ្ចិត ៧០មម ចំនួន៥ និង៨០មម ចំនួន ៥ទៀតក្នុងមួយពណ៌។ យកកំណាត់ពណ៌ដែលបានកាត់រួចមកមូរជារាងសាជី រួចដេរឱ្យជាប់។



៥. បន្ទាប់មកយកកំណាត់ដែលដេររួច មកចងបន្តគ្នាទម្លាក់ចុះ ចំនួន២ឬ៣ និងដាក់ឆ្លាស់ពណ៌ បន្តបន្ទាប់គ្នា ដើម្បីទារកបានមើលឃើញទាំងអស់ ។ កំណត់សម្គាល់: រំយោលនេះ ប្រសិនជាយើងអាចបត់ក្រដាសធ្វើ ជារូបសត្វចាប ឬជារង្វង់ក៏បាន អាស្រ័យលើភាពប៉ិនប្រសប់របស់ឪពុក ម្តាយ ឬអ្នកថែទាំទារក/កុមារ ។





៦. ការរៀបចំបានជារំយោលរួចហើយ យករំយោលទាំងនោះ ទៅចងព្យួរលើអង្រឹងឱ្យខ្ពស់ផុតពីដៃទារក ដើម្បីទុកឱ្យទារកបានមើល ។ រំយោលទាំងនោះនឹងធ្វើចលនារេចុះឡើង និងទៅតាមខ្យល់បក់ ឬការរំជួយរបស់អង្រឹង ។ ចលនានៃរំយោលបានធ្វើឱ្យទារកមានការចាប់អារម្មណ៍ និងសប្បាយរីករាយ ។

៧. សូមសួរបើសិនមានសំណួរផ្សេងៗ

៨. អ្នកសម្របសម្រួលអាចប្រាប់ដល់សិក្ខាកាមផងដែរថា ឪពុកម្តាយ ឬអ្នកថែទាំទារកអាចទិញប្រដាប់ក្មេងលេងដូចជា រំយោលដែលមានលក់នៅលើទីផ្សារ ឱ្យទារកលេងបានផងដែរ ។

**សង្ខេបមេរៀន:** អ្នកសម្របសម្រួល ស្នើឱ្យសិក្ខាកាមម្នាក់រៀបរាប់ពីរបៀបផលិតរំយោលសម្រាប់ទារកលេង ។

**ការវាយតម្លៃ:** ហេតុអ្វីបានការព្យួររំយោលនេះ? តើរំយោលមានសារៈសំខាន់ ចំពោះកុមារអ្វីខ្លះ?

**ឯកសារយោង:**

*១. គម្រោងកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកស្ម័គ្រចិត្តសុខភាពភូមិ ស្តីពីទម្លាប់អនុវត្តរបស់គ្រួសារ នៃសមាហរណកម្ម ការទទួលបន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ ពង្រាង ខែមិថុនា ឆ្នាំ ២០០៤ ម៉ូឌុលទី៦ មេរៀនទី៦ ។*

**មេរៀនទី ៧: ការផលិតរថយន្ត/ឡាន (ជម្រើស)** **រយៈពេល: ១ម៉ោង ៣០នាទី**

**វត្ថុបំណងនៃការសិក្សា:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាចៈ

១. ធ្វើឡាន សម្រាប់កុមារអាយុពី ៣ ដល់ ៥ឆ្នាំលេង។

**សម្ភារៈជំនួយបង្រៀន:**

- សម្រាប់សិក្ខាកាមម្នាក់ៗ: គម្របដបទឹកសុទ្ធចំនួន ៤ ដបទឹកសុទ្ធចំនួន ១ បំពង់បឺត ចំនួន ២ ក្រដាសពណ៌ស្កុត បន្ទះឫស្សី កាំបិត និងកន្ត្រៃ។

**វិធីសាស្ត្របង្រៀន:**

- បង្ហាញពីការផលិតសម្ភារៈល្បែងសម្រាប់កុមារលេង និងការអនុវត្ត

**ជំហានសកម្មភាព:**

**បងាញវតបំណងរួម**

**សេចក្ដីផ្ដើម:** នៅក្នុងសកម្មភាពនេះ យើងនឹងបង្កើតសម្ភារៈលេងមួយ សម្រាប់កុមារដែលមានអាយុ ចាប់ពី ៣ ទៅ ៥ឆ្នាំអាចលេងបាន។

១. បង្ហាញវត្ថុផ្សេងៗសម្រាប់ផលិតរថយន្ត (ឡាន) ដែលត្រូវផលិតសម្រាប់ សិក្ខាកាមម្នាក់ៗ (ដប/គម្របដបទឹកសុទ្ធ ឫស្សី បំពង់បឺត ស្កុត ខ្សែ)



២. ប្រើកន្ត្រៃ ឬកាំបិត ចោះរុន្ធតូចមួយនៅចំកណ្ដាលនៃ គម្របដបទឹកសុទ្ធទាំង៤ (កង់ឡានអាចយក សំបកដបទឹកសុទ្ធ ផ្លែក្រសាំង ឬផ្លែរលោះក៏បាន)



៣. យកឫស្សីមកបិតឱ្យមូលល្មមដោតចូលរន្ធសំបក ឬគម្របដបទឹកសុទ្ធទាំងនោះ ចំនួន២



៤. យកដបទឹកសុទ យកមកធ្វើជាតួឡាន ដោយយកកន្ត្រៃចោះរន្ធទម្លុះពីម្ខាងទៅម្ខាងទៀត ដែលមានទំហំរន្ធតូចល្មមអាចស៊កឫស្សីចូលដបទឹកសុទ្ធនោះ ធ្វើឱ្យកង់ឡានអាចវិលបាន ដើម្បីដាក់កង់មុខ និងកង់ក្រោយនៃឡាន។



៥. កាត់ក្រដាសពណ៌ ធ្វើជាកញ្ចក់ឡាន និងកាត់ជារូបរាងផ្សេងៗ ដើម្បីតុបតែងលំអលើសំបកដបដែលបានចោះរួចឱ្យបានស្អាត និងមានសោភ័ណ ដើម្បីទាក់ទាញកុមារឱ្យចាប់អារម្មណ៏ឡាននោះ

៦. យកឫស្សីទាំង២ ដែលមានដោតកង់១ រួចមកស៊កចូលក្នុងតួដបទឹកដែលបានចោះរន្ធរួចពីម្ខាងទៅម្ខាងទៀតទាំងផ្នែកខាងមុខ និងខាងក្រោយនៃតួឡាន។ បន្ទាប់មកទៀតយកគំរបដបចំនួន២ទៀតមកដោតជាប់នឹងចុងឫស្សីម្ខាងទៀតធ្វើជាកង់ឡាន។ កំណត់សម្គាល់ៈសម្ភារៈដែលយកមកប្រើប្រាស់ក្នុងការធ្វើឡានសម្រាប់ឱ្យកុមារលេងត្រូវប្រាកដថាមានអនាម័យ និងសុវត្ថិភាពចំពោះកុមារ





៧. យកខ្សែនីឡុងមកចងនឹងមាត់ដប សម្រាប់ឱ្យកុមារអូសលេង។

៨. សូមសួរបើសិនមានសំណួរផ្សេងៗ

៩. អ្នកសម្របសម្រួលអាចប្រាប់ដល់សិក្ខាកាមផង ដែរថា ពួកគេអាចយកវត្ថុផ្សេងៗទៀត មកផលិតជាឡានបាន ។



**សង្ខេបមេរៀន:** អ្នកសម្របសម្រួលសួរសិក្ខាកាមថាមានប្រដាប់កុមារលេងអ្វីផ្សេងទៀតដែលពួកគេអាចធ្វើបាន ដោយប្រើប្រាស់សម្ភារៈងាយៗដែលមាននៅតាមមូលដ្ឋាន ។

គំនិតផ្សេងៗ រួមមាន:

- ខ្លែងធ្វើអំពីឫស្សី ក្រដាស ខ្សែ ឬថង់ផ្លាស្ទិក និងខ្សែអំបោះនីឡុង
- សត្វជើងបួន ឬកូនក្រមុំធ្វើពីកំទេចកំណាត់
- យន្តហោះក្រដាស ។ល ។

លើកទឹកចិត្តសិក្ខាកាម នូវការស្រមើស្រមៃរបស់ពួកគេ..!

គេអាចធ្វើសម្ភារៈជាច្រើនសម្រាប់កុមារលេង តាមដែលកុមាររីករាយ និងលេងជាមួយវត្ថុទាំងនោះ ។

**ការវាយតម្លៃ:** អ្នកសម្របសម្រួល សួរសិក្ខាកាមម្នាក់អំពីរបៀបធ្វើឡានឱ្យកុមារអាយុចាប់ពី ៣ ទៅ ៥ឆ្នាំលេង ។

**ឯកសារយោង:**

*១. គម្រោងកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកស្ម័គ្រចិត្តសុខភាពភូមិ ស្តីពីទម្លាប់អនុវត្តរបស់គ្រួសារនៃសមាហរណកម្ម ការទទួលបន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ. ៣ម៉ោង ខែមិថុនា ឆ្នាំ ២០០៤ ម៉ូឌុលទី៦ មេរៀនទី៨ ។*

## មេរៀនទី ៨: សង្ខេបម៉ូឌុល និងការធ្វើតេស្តក្រោយពេលសិក្សា រយៈពេល ៣០នាទី

**វត្ថុបំណងនៃការសិក្សា:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាចៈ

១. រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ

២. វាយតម្លៃចំណេះដឹងក្រោយវគ្គសិក្សា តាមរយៈការធ្វើតេស្តក្រោយពេលសិក្សា

**សម្ភារៈជំនួយបង្រៀន:**

- ក្រដាសផ្ទាំងធំ មានសរសេរពីវត្ថុបំណងម៉ូឌុល ក្រដាសផ្ទាំងធំ មានសារគន្លឹះសម្រាប់ម៉ូឌុលនេះ
- ហ្វឺតសម្រាប់សរសេរ បង់ស្អិត បញ្ជីសំណួរសម្រាប់ធ្វើតេស្តក្រោយពេលសិក្សា

**វិធីសាស្ត្របង្រៀន:**

- ពិភាក្សាក្រុម
- តេស្តក្រោយវគ្គសិក្សា

**ជំហានសកម្មភាព:**

**បង្ហាញពីវត្ថុបំណងរួម:**

**សេចក្តីផ្តើម:** អ្នកសម្របសម្រួលពន្យល់ថា នេះគឺជាមេរៀនចុងក្រោយសម្រាប់ម៉ូឌុលនេះ។

**វត្ថុបំណងទី១: រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ (១៥នាទី)**

- **ពិក្សាក្រុម**

- អ្នកសម្របសម្រួល ដឹកនាំសិក្ខាកាមពិភាក្សាពីចំណុចសង្ខេប និងសារគន្លឹះសម្រាប់ម៉ូឌុលនេះ។ អ្នកសម្របសម្រួលត្រូវបិទសារគន្លឹះនៅលើក្រដាសផ្ទាំងធំ ដើម្បីឱ្យសិក្ខាកាមមើល និងអាន។
- បន្ទាប់មក អ្នកសម្របសម្រួលសួរសិក្ខាកាមថា តើមានសំណួរអ្វីទេ?

**វត្ថុបំណងទី ២: វាយតម្លៃចំណេះដឹងតាមរយៈការធ្វើតេស្តក្រោយពេលសិក្សា (១៥នាទី)**

អ្នកសម្របសម្រួលប្រាប់សិក្ខាកាមថា មុននឹងយើងបញ្ចប់ម៉ូឌុលនេះ យើងនឹងធ្វើតេស្តក្រោយពេលសិក្សាខ្លីមួយ។ តេស្តនេះគឺដូចគ្នានឹងតេស្តមុនពេលសិក្សាដែលអ្នកទាំងអស់គ្នាបានធ្វើមុនចាប់ផ្តើមម៉ូឌុលនេះដែរ។ ការធ្វើតេស្តបែបនេះ គឺដើម្បីវាស់ពីចំណេះដឹងសិក្ខាកាមនៅមុននឹងក្រោយពេលសិក្សា ដើម្បីចង់ដឹងថា តើអ្នកទាំងអស់គ្នាបានទទួលចំណេះដឹងប៉ុណ្ណាពីវគ្គនេះ។ ដូច្នេះសូមកុំព្រួយបារម្ភ ប្រសិនបើអ្នកមិនចេះសំណួរណាមួយនោះ។ បន្ទាប់មក ចែកសំណួរតេស្តដល់សិក្ខាកាម។ ក្រោយពីសិក្ខាកាមបានធ្វើតេស្តក្រោយពេលសិក្សាចប់ អ្នកសម្រប

សម្រួលត្រូវបូកសរុបចម្លើយ ហើយប្រៀបធៀបនឹងលទ្ធផលតេស្តមុនពេលសិក្សា។

## សំណួរសម្រាប់ធ្វើតេស្តក្រោយពេលសិក្សា

សំណួរ "ត្រូវ ឬ ខុស" (សំណួរត្រូវ ត្រូវបានបង្ហាញក្នុងប្រអប់ខៀវ)

| | | |
|---|---|---|
| ១. កុមារត្រូវការការជំរុញលើកទឹកចិត្ត (ការលេង ការជជែក ការរៀន) ដើម្បីឱ្យសប្បាយរីករាយ និងមានសុខភាពល្អ | ត្រូវ | ខុស |
| ២. កុមារដែលមានសុខភាពល្អ ហើយទទួលបាននូវក្តីស្រឡាញ់ នៅពេលកុមារនោះធំពេញវ័យ គេក៏អាចផ្តល់នូវក្តីស្រឡាញ់នោះដល់អ្នកដទៃទៀតដែរ | ត្រូវ | ខុស |
| ៣. សម្ភារៈសម្រាប់កុមារលេងមានសារៈសំខាន់ណាស់ ព្រោះសម្ភារៈទាំងនោះអាចជួយជំរុញដល់ស្មារតីរបស់កុមារ និងជួយឱ្យគេមានការលូតលាស់ផ្នែកបញ្ញា (ការគិត) | ត្រូវ | ខុស |
| ៤. ការញញឹម គឺជាមធ្យោបាយក្នុងការប្រាស្រ័យទាក់ទងដ៏សំខាន់មួយសម្រាប់ទារក និងកុមារ | ត្រូវ | ខុស |
| ៥. ទារក/កុមារត្រូវការសេចក្តីស្រឡាញ់ និងការថ្នាក់ថ្នមច្រើនដូចគ្នា | ត្រូវ | ខុស |
| ៦. ទារក/កុមារអាយុ ៧ខែ អាចធ្វើត្រាប់តាមសំលេង និងទឹកមុខរបស់មនុស្សធំ | ត្រូវ | ខុស |
| ៧. ទារក/កុមារអាយុ ១២ខែ អាចចាប់យកវត្ថុផ្សេងៗដោយម្រាមដៃ | ត្រូវ | ខុស |
| ៨. សុខភាពផ្លូវចិត្តរបស់ទារក/កុមារ មិនមានសារៈសំខាន់ដូចសុខភាពរាងកាយរបស់គេទេ | ត្រូវ | ខុស |
| ៩. ការស្រែកគំហក ការទះបន្តិចបន្តួច ពុំមែនជាអំពើហិង្សាទេ | ត្រូវ | ខុស |
| ១០. ការលង់ទឹក ជាពិសេសនៅស្រះទឹក អណ្តូងទឹក គឺជាមូលហេតុចម្បងដែលបណ្តាលឱ្យកុមារមានអាយុ ១-៤ ឆ្នាំស្លាប់នៅកម្ពុជា | ត្រូវ | ខុស |
| ១១. ប្រសិនបើទារក/កុមារមានការលូតលាស់ខុសពីទារក/កុមារដទៃ ឪពុកម្តាយគួរតែចាំមើលសិន ព្រោះវានឹងបាត់ទៅវិញដោយខ្លួនឯង។ | ត្រូវ | ខុស |